ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១៧ សហវ.ពដ

# សេចក្តីជូនដំណឹង

## ស្តីពី

## បែបបទបង់ប្រាក់ពន្ធអាករសម្រាប់អ្នកជាប់ពន្ធមធ្យម

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក/លោកស្រី ដែលជាបណ្ណាធិការ ឬកម្មសិទ្ធិករ សហគ្រាស ក្រុមហ៊ុន ទាំងអស់ឱ្យបានជ្រាបថា ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០១ រហូតមក សហគ្រាស ក្រុមហ៊ុន ដែលជាអ្នកជាប់ពន្ធស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃការិយាល័យប្រមូលពន្ធតាមរបបពិត នៅរាជធានីភ្នំពេញ បានធ្វើការបង់ប្រាក់ពន្ធអាករនានានៅធនាគារជាតិនៃកម្ពុជា ។

ក្នុងគោលដៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ តទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមកំណត់បែបបទនៃការបង់ប្រាក់ពន្ធអាករនានារបស់ សហគ្រាស ក្រុមហ៊ុន ទាំងអស់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធមធ្យមនៃការិយាល័យប្រមូលពន្ធតាមរបបពិតនៅរាជធានីភ្នំពេញ ដូចខាងក្រោម :

១- ការបង់ប្រាក់ពន្ធអាករជាសាច់ប្រាក់ ( Cash Payment ) ត្រូវធ្វើដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា ។

២- ការបង់ប្រាក់ពន្ធអាករដោយប្រើមូលប្បទានបត្រ ( Cheque ) អាចធ្វើបាននៅធនាគារជាតិនៃកម្ពុជា ឬនៅការិយាល័យប្រមូលពន្ធតាមរបបពិតក៏បាន ។

៣- ការបង់ប្រាក់ពន្ធអាករដោយវិធីផ្ទេរគណនីធនាគារ ( Transfer of Bank Account ) ត្រូវផ្ទេរចូលក្នុងគណនីនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជាដូចខាងក្រោម :

- ប្រាក់រៀល : គណនីលេខ 0100-39.1211-T112
- ប្រាក់ដុល្លារអាមេរិក : គណនីលេខ 0102-35.1211-T127 ។

ក្រោយការបង់ប្រាក់ពន្ធអាករ លោក/លោកស្រីត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធដែលចេញដោយធនាគារជាតិនៃកម្ពុជាភ្ជាប់ជាមួយនិងលិខិតប្រកាសសារពើពន្ធ ដាក់ជូនការិយាល័យប្រមូលពន្ធតាមរបបពិត ទៅតាមកាលកំណត់ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី អនុវត្តតាមខ្លឹមសារនៃលិខិតជូនដំណឹងនេះឱ្យបានល្អប្រសើរ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៤

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត់ ចន្ថុល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427798